Take Free!!
Map & Coupon 付

# NyoNyum ញញឹម

「この国」を伝える。カンボジア生活情報誌「ニョニュム」
Cambodian Life Navigation in Japanese and English

104th
Dec 2019 / Jan 2020
https://nyonyum.net




## 水とともに生きる

〜「みんなのための水」の実現のために〜

រក្សាសិទ្ធិគ្រប់បែបយ៉ាង រាល់ការថតចម្លងដោយគ្មានការអនុញ្ញាត នឹងត្រូវផ្តន្ទាទោសតាមច្បាប់

©Stef 2019, Happy Painting

# ការអភិវឌ្ឍវិស័យទឹកស្អាតនៅកម្ពុជា

## ដើម្បីសម្រេចបាននូវ "ទឹកស្អាតសម្រាប់អ្នកទាំងអស់គ្នា"

តើអ្នកទាំងអស់គ្នា ធ្លាប់ញ៉ាំទឹកស្អាតនៅភ្នំពេញផ្ទាល់ដែរឬទេ ?
គេនិយាយថា នៅប្រទេសក្នុងតំបន់អាស៊ាន មានតែប្រទេសសាំងកាពួរមួយគត់
ដែលមានទឹកស្អាតអាចញ៉ាំផ្ទាល់បាន ក៏ប៉ុន្តែតាមពិតទៅ ទឹកស្អាតក្នុងទីក្រុងភ្នំពេញ
គឺមានកម្រិតស្តង់ដាអាចញ៉ាំបានផងដែរ។
ហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសកម្ពុជា ត្រូវបានខ្ទេចខ្ទាំដោយសារ
សង្គ្រាមស៊ីវិលដែលអូសបន្លាយជាយូរ។ នៅក្នុងស្ថានភាពនោះផងដែរ
មានការងារផ្គត់ផ្គង់ទឹកស្អាតដែលចាំបាច់សម្រាប់ជីវភាពរស់នៅរបស់មនុស្សគ្រប់រូប។
ដើម្បីសម្រេចបាននូវបំណងប្រាថ្នានោះ រដ្ឋាភិបាលកម្ពុជានិងជប៉ុនបាន
រួបរួមគ្នាផ្តួចផ្តើមនូវគម្រោងស្តារនិងអភិវឌ្ឍនោះឡើង។
យើងខ្ញុំនឹងធ្វើការពិពណ៌នាអំពីប្រវត្តិនៃរឿងរ៉ាវនៃគម្រោងនោះ!



# ចង់ផ្គត់ផ្គង់ "ទឹកស្អាត" ដល់អ្នកទាំងអស់គ្នា

ទឹកជាប្រភពនៃជីវិត។ វាតែងតែនៅក្បែរយើងជាប្រចាំ ហើយពេលខ្លះវាក៏ជាការគំរាមកំហែងផងដែរ ហើយមនុស្សបានអភិវឌ្ឍមកក៏ដោយសារទទួលបាននូវគុណបុណ្យនៃទឹកនេះ។ ក៏ប៉ុន្តែមានគេនិយាយថា នៅលើពិភពលោកមានមនុស្សប្រមាណ ២១០០លាននាក់ (មាន ១នាក់ក្នុងចំណោម ៤នាក់) ពុំទាន់មាន "ទឹកស្អាត" ប្រើប្រាស់។ នៅប្រទេសកម្ពុជា "ការទទួលបានទឹកស្អាតប្រើប្រាស់" ក៏ត្រូវបានរដ្ឋាភិបាលចាត់ជាបញ្ហាចម្បងបំផុតមួយផងដែរ។

នៅក្នុងគោលដៅ ១ ក្នុងចំណោមគោលដៅទាំង ១៧ នៃ "គោលដៅអភិវឌ្ឍចិរភាព (SDGs)" ដែលកំណត់ដោយអង្គការសហប្រជាជាតិបានលើកឡើងថា "នឹងផ្តល់ទឹកស្អាតនិងបង្គន់អនាម័យនៅទូទាំងពិភពលោក"។ នៅក្នុង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍថ្នាក់ជាតិ( National Strategic Development Plan)" នៃប្រទេសកម្ពុជាបានចាប់ផ្តើមការផ្តួចផ្តើមសំដៅសម្រេច SDGs ដោយលើកឡើងនូវការលើកកម្ពស់ថ្នាក់ជាតិនៃការផ្គត់ផ្គង់ទឹកស្អាត។

ការផ្តួចផ្តើមដំបូងនេះ ត្រូវបានផ្តោតអារម្មណ៍លើទឹកនៅទីក្រុងភ្នំពេញ។ ការសម្រេចបាននូវ "ទឹកស្អាតទីក្រុងភ្នំពេញ" ត្រូវបានគេហៅថា "អច្ឆរិយនៃភ្នំពេញ" នោះ ត្រូវបានសម្រេចគោលដៅដោយឆ្លងកាត់ការខិតខំប្រឹងប្រែងដ៏លំបាកផ្សេងៗ។ នោះជាលទ្ធផលនៃការរៀបចំហេដ្ឋារចនាសម្ព័ន្ធដោយជំនួយអន្តរជាតិ និងការសហប្រតិបត្តិការជាង ២០ឆ្នាំ នៃរដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu។ ជាងនេះទៅទៀត សមិទ្ធផលនោះកើតឡើងដោយសារការខិតខំប្រឹងប្រែងរបស់បុគ្គលិកទាំងឡាយ បំរើការទាក់ទងនឹងការងារទឹកស្អាតកម្ពុជាផងដែរ។ ឯកឧត្តម ឯក សុនចាន់ ដែលជាអតីតអគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) ដែលបានបង្កើតប្រវត្តិការងារនោះបានទទួល "ពានរង្វាន់ រ៉ាមុន ម៉ាកសេយសេយ" ដែលជាពានរង្វាន់ល្បីបែលប្រចាំអាស៊ីនៅឆ្នាំ២០០៦។ ម៉្យាងទៀត PPWSA ក៏ត្រូវបានជ្រើសរើសជា "ពានរង្វាន់ឧស្សាហកម្មទឹកស្អាត" ដែលជារង្វាន់ផ្តួចផ្តើមការគ្រប់គ្រងទឹកដ៏ប៉ិនប្រសប់នៅលើពិភពលោកក្នុងឆ្នាំ២០១០។




## គោលដៅអភិវឌ្ឍចិរភាព SDGs

Sustainable Development Goals

ជាការអនុវត្តន៍បន្តនៃគោលដៅអភិវឌ្ឍសហសវត្សន៍ដែលត្រូវបានកំណត់នៅឆ្នាំ២០០១ ហើយត្រូវបានចុះផ្សាយជា "របៀបវារៈឆ្នាំ២០៣០ ដើម្បីការអភិវឌ្ឍចិរភាព" ដែលត្រូវបានសម្រេចជ្រើសរើសនៅឯកិច្ចប្រជុំសហប្រជាជាតិនៅខែកញ្ញា ឆ្នាំ២០១៥។ វាមានរចនាសម្ព័ន្ធពីគោលដៅចំនួន ១៧ និង ទិសដៅចំនួន ១៦៩ ដើម្បីសម្រេចបាននូវការអភិវឌ្ឍចិរភាព ដោយសច្ចាថានឹងមិនបោះបង់ចោលនូវជនណាម្នាក់ឡើយ។ SDGs មិនត្រឹមតែនៅប្រទេសកំពុងអភិវឌ្ឍប៉ុណ្ណោះទេ វាជាការផ្តួចផ្តើមសកលនៃបណ្តាប្រទេសអភិវឌ្ឍជឿនលឿន ហើយប្រទេសជប៉ុនក៏ចូលរួមយ៉ាងសកម្មនៅក្នុងការផ្តួចផ្តើមនេះផងដែរ។ (ពីគេហទំព័ររបស់ក្រសួងការបរទេសជប៉ុន)




## "អច្ឆរិយក្រុងភ្នំពេញ"

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) បានធ្វើឱ្យប្រសើរឡើងយ៉ាងឆាប់រហ័សនូវ "កម្រិតចំណុះបរិមាណទឹកបាត់បង់ (ជាចំនួនភាគរយនៃចំណុះទឹកដែលពុំអាចប្រមូលប្រាក់ ដោយសារការលេចធ្លាយទឹកជាដើមនៅពេលចែកចាយ)" នៅក្រោយការបញ្ចប់សង្គ្រាមស៊ីវិលពី ៧២% (១៩៩៣) មកត្រឹម ៨% (២០០៣) ហើយនៅខែឧសភា ឆ្នាំ២០០៥ បានធ្វើការប្រកាសថា "ទឹកដែលអាចញ៉ាំបាន" ដោយអាចឱ្យប្រជាពលរដ្ឋពិសារទឹកស្អាតបានផ្ទាល់ចេញពីក្បាលរ៉ូប៊ីណេទឹកដែលពួកគាត់ប្រើប្រាស់។ "អច្ឆរិយនៃភ្នំពេញ" ត្រូវបានកោតសរសើរដោយលទ្ធផលដ៏គួរឱ្យភ្ញាក់ផ្អើលនោះ។ សមិទ្ធផលដ៏អស្ចារ្យនេះកើតឡើងដោយការសហការនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងជំនួយពីប្រទេសដូចជា៖ ជប៉ុននិងបារាំងជាដើម អស់រយៈពេលជាង ១០ឆ្នាំ ហើយត្រូវបានបោះពុម្ពនៅក្នុងសៀវភៅផ្សព្វផ្សាយលេខ ១៣ នៃ "ប្រវត្តិសាស្ត្រនៃគម្រោង" របស់ JICA ស្តីពី "អច្ឆរិយនៃភ្នំពេញ កំណែទម្រង់ទឹកស្អាតនៅកម្ពុជាដែលនាំឱ្យពិភពលោកភ្ញាក់ផ្អើល"។






# ទឹកនៅប្រទេសកម្ពុជា និងក្រុង Kitakyushu

## ទំនាក់ទំនងប្រវត្តិសាស្ត្រទឹកស្អាតនៅប្រទេសកម្ពុជា

នៅឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានចាប់ផ្តើមដំណើរការនៃការស្តារឡើងវិញនូវការអភិវឌ្ឍ បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមស៊ីវិលអូស-បន្លាយជាយូរ។ ពេលនោះមានហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទត្រូវបានបំផ្លាញ ហើយទឹកស្អាតដែលជាអាយុជីវិតនៃមនុស្សទូទៅក៏ទទួលការរងខូចខាតជាខ្លាំងផងដែរ។ ការផ្គត់ផ្គង់ទឹកស្អាតពីរោងចក្រទឹកស្អាត ភូមិព្រែក នៅទីក្រុងភ្នំពេញ មានត្រឹមតែ ៤០% ដោយ ១ថ្ងៃផ្គត់ផ្គង់បានត្រឹមតែ ១០ម៉ោងប៉ុណ្ណោះ ហើយបំពង់បង្ហូរទឹកក៏ចាស់រេចរិលផងដែរ។

មានទឹកល្អក់ចេញពីបំពង់បង្ហូរទឹកដែលធ្វើឱ្យសំលៀកបំពាក់ឡើងពណ៌ល្អក់បន្ទាប់ពីបោកគក់ហើយ។ នៅតំបន់ដែលពុំមានទឹកស្អាតប្រើប្រាស់វិញ មានរទេះដឹកធុងទឹកធំៗរុញដោយក្មេងនិងមនុស្សជំទង់ដើម្បីយកមកប្រើប្រាស់។ ពួកគាត់យកទឹកដែលដឹកនោះមកចាក់បំពេញពាងទឹក ឬអាងស្តុកទឹកដែលនៅមុខផ្ទះរបស់ខ្លួន ហើយប្រើប្រាស់ទឹកនោះដោយសន្សំសំចៃ ក្នុងការបោកសំលៀកបំពាក់ លាងចានឆ្នាំង និងទុកមុជជាដើម។ ក្នុងនោះក៏មានអ្នកខ្លះលួចភ្ជាប់បំពង់បង្ហូរទឹកពីបំពង់បង្ហូរទឹករដ្ឋមកប្រើប្រាស់ក៏មានផងដែរ។ យើងបានឃើញពីស្ថានភាពកង្វះទឹកប្រើប្រាស់ជាប្រចាំបែបនោះនៅប្រទេសកម្ពុជា។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពបែបនេះ រដ្ឋាភិបាលប្រទេសជប៉ុននិងបារាំង ធានាគារពិភពលោក និងធានាគារអភិវឌ្ឍអាស៊ីជាដើម បានចាប់ផ្តើមជំនួយស្តារឡើងវិញនូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកម្ពុជា។ មានការចាប់ផ្តើមនូវការជួលជុលជាបន្ទាន់នូវរោងចក្រទឹកស្អាត ភូមិព្រែក ការដ្ឋានសំណង់កែប្រែថ្មីនៃបំពង់ទឹកស្អាត ហើយរួមជាមួយគ្នានោះក៏មានភាពចាំបាច់នៃការបង្កើតនូវប្រព័ន្ធគ្រប់គ្រងសំណង់ទាំងនោះ និងធនធានមនុស្សសម្រាប់ថែទាំនិងគ្រប់គ្រងផងដែរ។


រោងចក្រទឹកស្អាត ភូមិព្រែក បន្ទាប់ពីជួសជុលហើយ

តាមតម្រូវការនោះ ក្រុង Kitakyushu ដែលជាអាជ្ញាធរមូលដ្ឋានមួយក្នុងប្រទេសជប៉ុន បានចូលរួមជួយដល់កម្ពុជា។ ចាប់តាំងពីឆ្នាំ១៩៩៩ មក មានការបញ្ជូនបុគ្គលិកជំនាញពីទីក្រុង Kitakyushu មកកាន់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហើយបានធ្វើការផ្តល់ជំនួយឯកទេសពីជប៉ុនស្របតាម "តម្រូវការ" ផ្ទាល់របស់ភាគីកម្ពុជា។

លោក KUBOTA Kazuya ជាបុគ្គលិកដំបូងគេដែលត្រូវបានបញ្ជូនពីរដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យក្រុង Kitakyushu មកកាន់ប្រទេសកម្ពុជា។ បើនិយាយពីប្រទេសកម្ពុជានាពេលនោះ មានតែរូបភាពនៃស្ថានភាព "គ្រោះថ្នាក់" ដូចជា៖ សង្គ្រាម គ្រាប់មីន ជម្ងឺអេដស៍ និងអារុធជាដើមតែប៉ុណ្ណោះ។ គាត់ជាវីរៈបុរសទឹកស្អាតម្នាក់ដែលបានមកកាន់ប្រទេសកម្ពុជា ដើម្បីជួយផ្តល់និងសាបព្រួសនូវបច្ចេកទេសក្នុងស្ថានភាពដ៏លំបាកនិងគ្រោះថ្នាក់បែបនោះ។ ដោយក្តីរំភើបជាមួយនឹងភាពមោះមុតរបស់មន្ត្រីទឹកស្អាតកម្ពុជាទាំងនោះដែលមានបំណង "ចង់ផ្តល់ទឹកស្អាតជូនដល់ប្រជាជនកម្ពុជាគ្រប់រូប" លោក Kazuya បានឆ្លងកាត់ការតស៊ូរស់នៅក្នុងប្រទេសកម្ពុជា ដែលមានភាសារបៀបរបបរស់នៅនិងធ្វើការខុសពីប្រទេសជប៉ុន។


ស្ថានភាពរទេះដឹកធុងទឹក


លោក KUBOTA Kazuya កំពុងណែនាំអ្នកឯកទេសកម្ពុជា (រូបស្តាំលើ ថតឆ្នាំ២០០៦)

# តើក្រុង Kitakyushu បានធ្វើអ្វីខ្លះ?



▶ លោក KIYAMA Satoshi ដឹកនាំការគ្រប់គ្រងនិងថែរក្សាសម្ភារៈអគ្គិសនី (ឆ្នាំ ២០០៤)

## “ធនធានមនុស្ស” ដែលបានបង្កើតអច្ឆរិយនៃភ្នំពេញ (ជំហានទី ១ ៖ ២០០៣ - ២០០៦)

ក្រុង Kitakyushu បានណែនាំដំបូងនោះ គឺការផ្ទេរបច្ចេកវិទ្យានៃ “តំបន់ចែកចាយទឹក” និង “ប្រព័ន្ធគ្រប់គ្រងការចែកចាយទឹក” ដែលត្រូវបាននាំមកដោយក្រុង Kitakyushu ជាវិធីសាស្ត្រគ្រប់គ្រងថែទាំនៃប្រព័ន្ធចែកចាយទឹក។ ដោយធ្វើការបែងចែកជា ៤១ តំបន់ចំពោះប្រព័ន្ធបំពង់ចែកចាយទឹកក្នុងក្រុងភ្នំពេញដែលមានប្រវែងសរុបប្រមាណ ១៣០០គីឡូម៉ែត្រ ដែលមានការតំឡើងនូវនាឡិកាវាស់ចំណុះលំហូរនិងនាឡិកាវាស់សម្ពាធទឹកតាមតំបន់នីមួយៗ ហើយធ្វើការបញ្ជូនទិន្នន័យត្រូវបានវាស់និងកត់ត្រារាល់ ១នាទីម្តងទៅកាន់ប្រព័ន្ធតេលេម៉ែត្រនិងឧបករណ៍ត្រួតពិនិត្យកណ្តាលដែលប្រើខ្សែរកាបអុបទិច។ ប្រព័ន្ធនេះសម្រាប់វាស់ចំណុះទឹកបាត់បង់ (ទឹកធ្លាយជាដើម) ហើយធ្វើការសម្រេចនូវការគ្រប់គ្រងនិងថែទាំនូវគ្រឹះស្ថានចែកចាយទឹកដែលមានប្រសិទ្ធភាពដោយការអនុវត្តន៍នូវការត្រួតពិនិត្យទឹកបាត់បង់ (ធ្លាយ/លេច) តាមតំបន់ដែលមានទិន្នន័យមិនល្អ។

ដោយមានការវាយតម្លៃខ្ពង់ពីលទ្ធផលនោះ នៅខែតុលា ឆ្នាំ២០០៣ គម្រោងសហប្រតិបត្តិការបច្ចេកទេស JICA ត្រូវបានចាប់ផ្តើមដោយការណែនាំរបស់រដ្ឋាករទឹកស្អាតក្រុង Kitakyushu។ មានការផ្តួចផ្តើមនូវការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់បំរើការនៅ PPWSA ក្នុងគោលបំណងកាត់បន្ថយនៃការបាត់បង់បរិមាណទឹក (ការលេចធ្លាយនិងលួចទឹក) ការផ្គត់ផ្គង់ទឹកទៀងទាត់ ការដំណើរការរោងចក្រទឹកស្អាតដ៏ត្រឹមត្រូវ ការធ្វើឱ្យប្រសើរឡើងនូវគុណភាពទឹកនិងការគ្រប់គ្រងថែទាំដ៏ត្រឹមត្រូវនៃសម្ភារៈអគ្គីសនីនិងម៉ាស៊ីន។ លើសពីនេះក៏មានការធ្វើឱ្យមានការរីកចំរើននូវបច្ចេកវិទ្យានៃមន្ត្រីទឹកស្អាតនៅកម្ពុជារួមជាមួយ OJT និងកម្មសិក្សាបច្ចេកទេសនៅប្រទេសជប៉ុនផងដែរ។ ការបង្កើតអាគារ និងសាងសង់រោងចក្រទឹកស្អាត គឺជាសកម្មភាពដែលទាមទាការអត់ធ្មត់និងពេលវេលាយូរ ក៏ប៉ុន្តែបើពុំមានការបណ្តុះបណ្តាលធនធានមនុស្សត្រឹមត្រូវនោះទេ ទោះជាសាងសង់គ្រឹះស្ថាន និងបរិក្ខាក៏ដោយក៏ពុំមានន័យនោះឡើយ។ ដោយយល់ឃើញនូវភាពចាំបាច់បែបនេះ ក្រុង Kitakyushu បានចាប់ផ្តើមនូវការបណ្តុះបណ្តាលនោះឡើងមក។

ជាលទ្ធិផល គេបានសម្រេចនូវគោលដៅនីមួយៗទាំងនោះបន្តិច-ម្តងៗ ហើយនៅប្រទេសជប៉ុនក៏ដោយ បើកំរិតចំណុះទឹកបាត់បង់ត្រូវបានថយចុះមកក្រោម ៨% នោះ នឹងត្រូវបានគេចាត់ទុកថាជាអង្គភាពសាជីវកម្មដ៏ល្អបំផុតមួយ។ បើប្រៀបធៀបនឹងឆ្នាំ ១៩៩៣ មានតួលេខដែលបង្ហាញពីសមិទ្ធផលទាំងនោះ។




▶ តារាងបង្ហាញពីចំណុះលំហូរទឹកចែកចាយ ដែលបង្ហាញនៅឯបន្ទប់ត្រួតពិនិត្យកណ្តាលនៃ PPWSA



◀ លោក TAKAYAMA Isshei ដឹកនាំកម្មសិក្សានៅក្រុង Kitakyushu (រូបទី ២ ពីឆ្វេង)

ជាពិសេសចំនុចគួរកត់សម្គាល់នោះគឺសមិទ្ធផលនៃស្ថេរភាពនៃការគ្រប់គ្រងរបស់ PPWSA។ ដោយសារមានអត្រាប្រមូលប្រាក់ប្រើប្រាស់ទឹកស្អាតបានកើនឡើង ទើបចាប់ពីឆ្នាំ២០០១ មក ទោះបីជាគ្មានការតម្លើងថ្លៃទឹកស្អាតក្តី ការគ្រប់គ្រងអង្គភាពមានស្ថេរភាពល្អ ហើយ PPWSA បានសម្រេចនូវគោលបំណងដែលបានលើកឡើងអំពី “ការផ្គត់ផ្គង់ទឹកស្អាតដល់ស្រទាប់ប្រជាពលរដ្ឋក្រីក្រ”។ តាមរយៈការផ្តល់នូវបំពង់ផ្គត់ផ្គង់ទឹកស្អាតដោយឥតសំណងទៅកាន់តំបន់ក្រីក្រជាដើម បានជួយបរិច្ចាកយ៉ាងធំធេងដល់វិធានការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

នេះជាមោទនភាពរបស់បុគ្គលិកនៃ PPWSA។ អតីតអគ្គនាយក PPWSA ឯកឧត្តម ឯក សុនចាន់ បានព្យាយាមកែប្រែការយល់ឃើញនិងបង្កើនសីលធម៌របស់បុគ្គលិក។ ការប្រកាសនៅមុខបុគ្គលិកគ្រប់-គ្នានូវការតាំងចិត្ត ដែលមានការកំណត់នូវគោលបំណងរួមរបស់ស្ថាប័ន ហើយតម្លើងប្រាក់ខែប្រសិនបើសម្រេចបានគោលដៅ ដោយការសន្យានូវសមិទ្ធផលជាក់លាក់នោះ បានធ្វើឱ្យបុគ្គលិកអង្គភាពទឹកស្អាតមានការខិតខំប្រឹងប្រែងចំពោះការងារពួកគេ។ ជំនួយពុំអាចមានប្រសិទ្ធភាពបានទេ ប្រសិនបើភាគីនៃប្រទេសជួយធ្វើតែឯងនោះ។ ដូច្នេះលទ្ធផលអាចសម្រេចទៅបាន លុះត្រាតែមានការខិតខំប្រឹង-ប្រែងធ្វើការងាររួមគ្នានៃអ្នកម្ចាស់ស្រុក។



◀ លោក KAGATA Katsutoshi ដឹកនាំពីការគ្រប់គ្រងនិងថែទាំម៉ាស៊ីនបូមទឹក (រូបខាងឆ្វេង ឆ្នាំ២០០៥)

### អច្ឆរិយនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

| ទិសដៅគម្រោង | ឆ្នាំ១៩៩៣ | ឆ្នាំ២០០៦ |
|---|---|---|
| ចំនួនបុគ្គលិក (ត្រូវនឹងចំនួនគ្រួសារផ្គត់ផ្គង់ទឹក ១០០០) | ២២ នាក់ | ៤ នាក់ |
| សមត្ថភាពផ្គត់ផ្គង់ទឹក (m³ / ថ្ងៃ) | ៦៥០០០ | ២៣៥០០០ |
| អត្រាផ្គត់ផ្គង់ទឹកស្អាត | ២៥% | ៩០% |
| រយៈពេលផ្គត់ផ្គង់ទឹក | ១០ ម៉ោង | ២៤ ម៉ោង |
| សម្ពាធទឹកផ្គត់ផ្គង់ជាមធ្យម | ០.២kgf/ cm² | ២.៥kgf/ cm² |
| ចំនួនគ្រួសារផ្គត់ផ្គង់ទឹក | ២៦៨៨១ គ្រួសារ | ១៤៧០០០ គ្រួសារ |
| អត្រាចំណុះទឹកបាត់បង់ | ៧២% | ៨% |
| អត្រាបង់ប្រាក់ប្រើប្រាស់ទឹកស្អាត | ៤៨% | ៩៩.៩% |

## ការពង្រីកទឹកស្អាតទៅកាន់តំបន់ជាមួយ PPWSA (ជំហានទី ២ ៖ ២០០៧ - ២០១២)

ក្រោយគម្រោងដែលមានសមិទ្ធផលធំមួយនៅទីក្រុងភ្នំពេញ ជាជំហានបន្ទាប់គឺការឆ្ពោះទៅកាន់ទីជនបទ។ នៅទីប្រជុំជនទាំង៨ (សូមមើលរូបផែនទីទំព័របន្ទាប់) ដែលមានរដ្ឋាករទឹកសាធារណៈដែលមានស្ថានភាពផ្គត់ផ្គង់ទឹកលំបាក ចាប់ពីខែឧសភា ឆ្នាំ២០០៧ មក ក្រុមការងារបានដំណើរការគម្រោងផ្គត់ផ្គង់ទឹកស្អាតដោយធ្វើការជួសជុលហេដ្ឋារចនាសម្ព័ន្ធ និងបណ្តុះបណ្តាលធនធានមនុស្ស



ទីក្រុងទាំង៨ក្នុងគម្រោងការជំហានទី២

ស្របគ្នា។ ចំពោះគម្រោងនេះ ត្រូវបានធ្វើឡើងជាមួយនឹងសកម្មភាពណែនាំបច្ចេកវិទ្យាដល់រដ្ឋាករទឹកនៅមូលដ្ឋានដោយបុគ្គលិកនៃរដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu និងបុគ្គលិក PPWSA ដែលមានបទពិសោធន៍ពីគម្រោងមុន។

ទឹកស្អាតនៅក្រុងនីមួយៗមានស្ថានភាពខុសៗគ្នា។ បើមើលពីប្រភពទឹកតែមួយក្តី មានក្រុងដែលមានប្រភពទឹកជាប្រភេទទឹកក្រោមដី ក្រុងដែលមានប្រភពទឹកជាទឹកទន្លេ និងក្រុងដែលមានផលវិបាកជាមួយប្រភពទឹកនៅតាមតំបន់មាត់សមុទ្រជាដើម។ ពោលគឺ វិធីសាស្ត្រដោះស្រាយទឹកស្អាតតាមតំបន់នីមួយៗ ការថ្លៃហេដ្ឋារចនាសម្ព័ន្ធ និងវិធីសាស្ត្រគ្រប់គ្រងមានភាពខុសគ្នា។ គេបានធ្វើការផ្ទាល់នឹងក្រុងនីមួយៗនោះបណ្តើរ សិក្សានូវស្ថានភាពទាំងនោះបណ្តើរ ហើយមានអ្នកជំនាញខាងចម្រោះទឹកស្អាត អគ្គីសនី ម៉ាស៊ីននិងគូរប្លង់ពីក្រុង Kitakyushu និងសហគ្រាសឯកទេសជប៉ុននានា ព្រមទាំងពីរដ្ឋបាលមូលដ្ឋានរបស់ជប៉ុន ជាច្រើនត្រូវបានបញ្ជូនមកផងដែរ។


លោក HIROWATARI Hiroshi ដឹកនាំការងារដាក់បំពង់បង្ហូរទឹក (រូបស្តាំ ឆ្នាំ២០១០)

លោក KIYAMA Satoshi ជាប្រធានគម្រោងពីមុនបានធ្វើដំណើរជាញឹកញាប់ទៅកាន់ក្រុងទាំង ៨ ក្នុងកំឡុងពេលអាណត្តិការងាររបស់លោក ហើយលោកបានក្តាប់នូវលក្ខណៈពិសេសនិងស្ថានភាពនៃតំបន់ បានស្នើសុំរដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu ដោយធ្វើការប្រជុំពិភាក្សាយ៉ាងល្អិតល្អន់ជាច្រើនលើកជាមួយ JICA និងក្រសួងសុខាភិបាលការងារនិងសុខមាលភាពសង្គមជប៉ុន ហើយក៏បានប្រមូលផ្តុំនូវកម្លាំងសហគ្រាសជប៉ុននានាទៀតផងដែរ។

ជាលទ្ធផល ក្រុមការងារបានកាត់បន្ថយបាននូវទឹកបាត់បង់ និងការចែកចាយទឹក ២៤ម៉ោងនៅទាំង ៨ ខេត្តដែលជាគោលដៅរបស់គម្រោង ហើយអាចផ្គត់ផ្គង់ទឹកដែលមានកម្រិតគុណភាពស្តង់ដាថ្នាក់ជាតិ។

---

## ឆ្ពោះទៅរកការងារគ្រប់គ្រងទឹកស្អាតដែលមានសុវត្ថិភាព (ជំហានទី ៣ ៖ ២០១២-២០១៨)

បន្ទាប់ពីគម្រោងនៃជំហានទី២ ដែលមានទិសដៅធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពផ្គត់ផ្គង់ទឹកស្អាត ដើម្បីអាចគ្រប់គ្រងដោយស្វ័យភាពបាន មានការសម្រេចពង្រីកគម្រោងបណ្តុះបណ្តាលធនធានមនុស្ស។ ចំពោះគម្រោងជំហានទី៣ ដែលចាប់ផ្តើមឡើងនាខែវិច្ឆិកា ឆ្នាំ២០១២ នេះបានអនុវត្តកម្មសិក្សាលក្ខណៈ OJT និងនៅឯឧស្សាហកម្មក្រុង Kitakyushu ចំពោះក្រសួងរ៉ែនិងថាមពល (ក្រសួងឧស្សាហកម្មនិងសិប្បកម្មសព្វថ្ងៃ) ដែលជាស្ថាប័នត្រួតពិនិត្យ ជាមួយរដ្ឋាករទឹកនៅក្រុងទាំង៨។ ដើម្បីបង្កើនសមត្ថភាពផ្នែកគ្រប់គ្រងការងារទឹកស្អាតគ្រប់ផ្នែក មានការកំណត់ផែនការគ្រប់គ្រងនិងហិរញ្ញវត្ថុ គណនេយ្យសហគ្រាស ការគ្រប់គ្រងព័ត៌មានអតិថិជន ការគ្រប់គ្រងព័ត៌មានទ្រព្យសម្បត្តិ ផែនការគ្រប់គ្រងថែទាំហេដ្ឋារចនាសម្ព័ន្ធ ការឆ្លើយតបនិងតម្រូវការរបស់អ្នករស់នៅ ការងារផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋការងារអភិរក្សប្រភពទឹកស្អាត និងផែនការបណ្តុះបណ្តាលធនធានមនុស្សជាដើម។ ហើយមានបញ្ចូលវត្ថុបំណងជាច្រើនយ៉ាងលំអិត ដើម្បីឆ្ពោះទៅកាន់ការគ្រប់គ្រងដ៏រឹងមាំ ដែលមានប្រព័ន្ធប្រាក់ចំណេញឯករាជ្យផងដែរ។

គម្រោងជំហានទី៣ មានលោក KAWASAKI Takayuki ជាប្រធានក្រុមដំបូង បានរំលឹករឿងពីអតីតកាលដូច្នេះថា៖ “កាលពីដំបូងមានបញ្ហាជាច្រើនដូចជា៖ ថវិការគ្រប់គ្រងក៏ពុំគ្រប់គ្រាន់ ហើយមានប្រព័ន្ធប្រមូលប្រាក់ដែលពុំស្មោះត្រង់ និងមានថវិការខាតចំនួន ៧ ក្រុង ក្នុងចំណោមក្រុងទាំង៨ ជាដើម។ ទោះជាយ៉ាងនោះក្តី ខ្ញុំនៅចាំបានថាមានការរាយការណ៍ពីរដ្ឋាករទឹកស្អាតនីមួយៗថា “ពុំមានបញ្ហាទេ” ដែលធ្វើឱ្យខ្ញុំភ្ញាក់ផ្អើលជាខ្លាំង។ ជាបឋម យើងត្រូវតែកែការយល់ឃើញខុសទាំងនោះ ហើយត្រូវតែបង្កើតជារួមនូវច្បាប់និងប្រព័ន្ធដែល “អាចមើលឃើញ” ដោយបានពិនិត្យពីទិសដៅ និងធ្វើការពិភាក្សាជាច្រើនដងនៅក្នុងគម្រោង។


លោក KAWASAKI ដឹកនាំការកំណត់ផែនការគ្រប់គ្រង និងហិរញ្ញវត្ថុ (រូបឆ្វេង ឆ្នាំ២០១៣)

លក្ខណៈពិសេសនៃគម្រោងនេះគឺ ការត្រួតពិនិត្យជាទៀតទាត់ដោយប្រើសចនករពីស្តង់ដា ដើម្បីធ្វើការវាយតម្លៃសមត្ថភាពនៃក្រុងទាំង៨។ តាមរយៈកាត្រួតពិនិត្យនោះ យើងអាចធ្វើការពិភាក្សាអំពីវិធានការដែលមានដូចជា៖ ថាតើផ្នែកអ្វីដែលរដ្ឋាករទឹកស្អាតនីមួយៗខ្វះខាត? មូលហេតុអ្វីនៃការខ្វះខាតនោះ? ហើយប្រការដែលចាំបាច់នោះជាថវិការ ឬការខិតខំប្រឹងប្រែង ឬធនធានមនុស្សជាដើម។ល។

ម្យ៉ាងវិញទៀត ឯកឧត្តម ឯក សុនចាន់ អតីតរដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានអនុវត្តសកម្មភាព “ចុះតាមខេត្ត” ដោយធ្វើដំណើរត្រួតពិនិត្យរដ្ឋាករទឹកស្អាតតាមតំបន់ដោយខ្លួនឯងដោយពុំពឹងផ្អែកអ្នកជំនាញជប៉ុន។ ពេលនោះវាបានធ្វើឱ្យបុគ្គលិកនៃរដ្ឋាករទឹកស្អាតទាំងអស់ ដែលរួមទាំងប្រធានរដ្ឋាករទឹកនៅតាមតំបន់មានការខ្នះខ្នែង។ នៅតាមបណ្តារដ្ឋាករទឹកស្អាតវិញ មានការធ្វើកម្មវិធីសិក្សាបន្ទាប់ពីបានពិនិត្យពីស្ថានភាពមូលដ្ឋានក្បោះក្បាយហើយ។ មានការបំភ្លឺពីវិធីសាស្ត្រកែប្រែបញ្ហា និងបានបង្កើតការតាមដានគម្រោងបន្ថែមទៀត។

ជាលទ្ធផលនៃការខិតខំប្រឹងប្រែង ថវិការប្រចាំឆ្នាំ២០១៥ នៃរដ្ឋាករទឹកស្អាតទាំង៨ ទទួលបាននូវប្រាក់ចំណេញ។ រដ្ឋាករទឹកស្អាតបានបន្សល់នូវប្រាក់ចំណេញតាមរយៈការកែប្រែការគ្រប់គ្រង ហើយបានឈានដល់ការសម្រេចបាននូវជំហានទីមួយនៃការគ្រប់គ្រងទឹកស្អាតដែលមានចិរភាពថែមទៀត ដោយការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មតាមរយៈការវិនិយោគសារជាថ្មី។

ក្រោយមក គម្រោងនេះត្រូវបានបន្តដោយលោក HIROWATARI Hiroshi ហើយរដ្ឋាករទឹកស្អាតប្រចាំតំបន់ត្រូវបានពង្រីកពី ៨ ក្រុងមកចំនួន១៣ ក្រុង។ មន្ត្រីជំនាញទាំងនោះបានធ្វើដំណើរគ្រប់តំបន់ទូទាំងប្រទេសកម្ពុជា ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពគ្រប់គ្រងនិងបច្ចេកវិទ្យាទាំងនោះ។

បុគ្គលិកនៃក្រុងនីមួយៗដែលមានការលើកទឹកចិត្តក្នុងកម្មសិក្សាគិតថា៖ “ត្រូវតែដេញតាមឱ្យទាន់ PPWSA”។ ពិតណាស់ មានរឿងជាច្រើនត្រូវធ្វើ ហើយវាពុំមែនជារឿងងាយស្រួលនោះឡើយ ក៏ប៉ុន្តែដើម្បីសម្រេចបាននូវពាក្យស្លោកដែលលើកឡើងថា៖ “Water for All = ទឹកសម្រាប់អ្នកទាំងអស់គ្នា” និង “ការសម្រេចបាន ១០០% នៃកំរិតអ្នកអាចប្រើប្រាស់ទឹកស្អាតដែលមានសុវត្ថិភាពនៅតាមទីប្រជុំជនរហូតដល់ឆ្នាំ ២០២៥” ដែលកំណត់ជាផែនការអភិវឌ្ឍយុទ្ធសាស្ត្រថ្នាក់ជាតិរបស់រដ្ឋាភិបាលកម្ពុជា ទោះបីជាគម្រោងបានបញ្ចប់នៅឆ្នាំ២០១៨ ហើយក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងនោះនៅតែបន្ត។

# អបអរសាទរខួបលើកទី ២០ !

ឆ្នាំនេះជាខួបលើកទី ២០ នៃការបញ្ជូនអ្នកជំនាញជប៉ុនលើកទី ១ នៅឆ្នាំ១៩៩៩ ពីរដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យក្រុង Kitakyushu ។ នាខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីអបអរសាទរខួបអនុស្សាវរីយនេះ មានការប្រារព្ធពិធីរំលឹកខួបអនុស្សាវរីយទ្រង់ទ្រាយធំនៅខេត្ត Kitakyushu ។

## ការជួបជុំនៅក្រុង Kitakyushu នៃក្រុមការងារទឹកស្អាតកម្ពុជា!

ក្រោយឆ្នាំ១៩៩៩ បុគ្គលិករដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu ចំនួនប្រមាណ ១៣០នាក់ ត្រូវបានបញ្ជូនមកកាន់ប្រទេសកម្ពុជា ហើយមានបុគ្គលិកពីកម្ពុជាចំនួនប្រមាណ ៩០នាក់ បានមកធ្វើកម្មសិក្សានៅក្រុង Kitakyushu ។ ការផ្លាស់ប្តូរធនធានមនុស្សដ៏យូយារនេះ ពុំអាចកើតឡើងបានដោយងាយនោះទេ។ ចំពោះអាជ្ញាធរមូលដ្ឋានជប៉ុនវិញ ការខិតខំប្រឹងប្រែងដ៏វែងឆ្ងាយដែលមានឫសគល់មូលដ្ឋាននៅប្រទេសកម្ពុជា អាចនិយាយបានថាជារឿងដ៏កម្រមួយ។

ដើម្បីអបអរសាទរខួបទី ២០ នៃកិច្ចសហប្រតិបត្តិការនៅកម្ពុជានេះ វេទិការទឹកស្អាតជប៉ុននិងកម្ពុជា ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩។ ពីភាគីកម្ពុជា មានវត្តមានដ៏ឧដុង្គឧត្តមពីសំណាក់មន្ត្រីជាន់ខ្ពស់នៃអង្គភាពទឹកស្អាតកម្ពុជា មានដូចជា៖ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឯកឧត្តម អ៊ុំ សុថា អនុរដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឯកឧត្តម ស៊ឹម ស៊ីថា អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញជាដើម បានអញ្ជើញចូលរួម ហើយភាគីជប៉ុនមាន៖ អភិបាលក្រុង Kitakyushu លោក KITAHASHI Kenji ប្រធានសភាក្រុង Kitakyushu លោក MURAKAMI Kouichi និងប្រធានក្រុមហ៊ុនរំរំផ៉រស៊ឺស Kitakyushu លោក ARITA Hitoshi បានចូលរួមទទួលស្វាគមន៍គណៈប្រតិភូកម្ពុជាដែលអញ្ជើញធ្វើទស្សនកិច្ចប្រទេសជប៉ុន។

ជាកិច្ចចាប់ផ្តើមនៃវេទិកា លោកអភិបាលក្រុង KITAHASHI បានមានប្រសាសន៍ថា៖ “ទីក្រុងរបស់យើង ត្រូវបានជ្រើសរើសជាលើកដំបូងនៅអាស៊ីពីអង្គការសហប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ច (OECD) ជា “ទីក្រុងគំរូលើពិភពលោកដែលជម្រុញ SDGs” ហើយយើងបានកំពុងខិតខំជម្រុញ SDGs ដែលក្រុងបានលើកឡើងកាលពីឆ្នាំមុន។ យើងខ្ញុំមានបំណងធ្វើកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចបាននូវការប្រើប្រាស់ទឹកស្អាតដែលមានសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋរស់នៅគ្រប់ទីប្រជុំជនទាំងអស់រហូតដល់ឆ្នាំ២០២៥”។

យ៉ាងណាមិញ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ បានមានប្រសាសន៍ថ្លែងអំណរគុណចំពោះការដឹកនាំ ដែលមានផ្លែផ្កាដ៏ធំធេងនៃសកម្មភាពទីក្រុង Kitakyushu ទាំងនៅទីក្រុងភ្នំពេញ និងតាមបណ្តាក្រុងនានា ចាប់តាំងពីអ្នកជំនាញជប៉ុនបានបញ្ជូនមកកម្ពុជានៅឆ្នាំ១៩៩៩ ហើយឯកឧត្តមក៏បានផ្ញើរសារដោយសង្កត់ធ្ងន់ថា៖ នាថ្ងៃអនាគតកម្ពុជាចង់បាននូវកិច្ចសហប្រតិបត្តិការទាំងអស់ពីក្រុង Kitakyushu ក្រសួងសុខាភិបាល ការងារនិងសុខុមាភាព ក្រសួងការបរទេស និងអង្គការ JICA រួមទាំងសហគ្រាសជប៉ុនផងដែរ។

នៅក្នុងវេទិកានោះ មានការចូលរួមពីសំណាក់ស្ថាប័ន និងសហគ្រាសពាក់ព័ន្ធនឹងការងារទឹកស្អាត និងសិស្សានុសិស្ស ប្រមាណជាង២០០នាក់ ដែលបានបង្ហាញពីការចាប់អារម្មណ៍ខ្លាំងលើអាជីវកម្មទឹកនៅប្រទេសកម្ពុជា។












ស្ថានភាពវេទិកាទឹកស្អាតជប៉ុន កម្ពុជា និងទស្សនកិច្ចពិនិត្យស្រាវជ្រាវស្ថាប័នក្នុងក្រុង។ ក្រៅពីនេះ គណៈប្រតិភូកម្ពុជាធ្វើទស្សនកិច្ចពិនិត្យស្ថានប័នទឹកស្អាតនិងសហគ្រាសជប៉ុនក្នុងក្រុងនាអំឡុងពេលស្នាក់នៅ។ នឹងមានការនាំនូវបច្ចេកវិទ្យាខ្ពស់ៗពីប្រទេសជប៉ុននិងចំណេះដឹងចំណេះធ្វើទៅកម្ពុជាឲ្យបានសកម្ម ហើយរំពឹងជាខ្លាំងថានឹងមានការរីកចំរើនថែមទៀតនៃវិស័យទឹកស្អាតរបស់ប្រទេសកម្ពុជា។

# ២០ឆ្នាំនៃទឹកស្អាត ជាមួយក្រុង Kitakyushu “មិត្តភាព” ជាប្រទេពនៃកម្លាំងជម្រុញ

ឯកឧត្តម ឯក សុនចាន់អតីតអគ្គនាយកនៃ PPWSA និងរដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្មនិងសិប្បកម្មដែលបានខិតខំប្រឹងប្រែងបំរើការងារទឹកស្អាតកម្ពុជាជាមួយក្រុង Kitakyushu រយៈពេលយូយារណាស់មកហើយ បានមានប្រសាសន៍អំពីទំនាក់ទំនងសហប្រតិបត្តិការបន្តមកដ៏យូរនោះ។



ឯកឧត្តម ឯក សុនចាន់
អតីតអគ្គនាយកនិងរដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម

ពេលខ្ញុំទទួលបានការអញ្ជើញពីលោក KUBOTA ដែលបានបញ្ជូនមកកាន់ PPWSA កាលពីឆ្នាំ១៩៩៩ ខ្ញុំបានទស្សនកិច្ចទឹកដី Kitakyushu ជាលើកដំបូង។ កាលនោះ ខ្ញុំបាននិយាយពិភាក្សាជាមួយលោក MORI Kazumasa ជាប្រធាននាយកដ្ឋាន (ក្រោយមកអគ្គនាយកនៃរដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu) អំពីការស្តារឡើងវិញនូវវិស័យទឹកស្អាតកម្ពុជា។ ការ “ជួបគ្នាបន្តិចបន្តួច” នោះ បាននាំឱ្យមានការចាប់ផ្តើមការងារសហប្រតិបត្តិការដែលពុំនឹកស្មានដល់។ ចាប់ពីពេលនោះមក ខ្ញុំបានធ្វើកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាផ្ទាល់មុខពីគ្រប់ជ្រុងជ្រោយ ជាមួយនឹងអ្នកជំនាញរយៈពេលវែងជាប្រវត្តិសាស្ត្រដែលមានដូចជា៖ លោក KIYAMA លោក ISHII លោក KAWASAKI លោក HIROWATARI។ មានការសាកសួរជាច្រើនទាក់ទងនឹង “មូលហេតុនៃភាពជោគជ័យ” ទាំងនោះតែដោយបញ្ចូលនូវស្មារតីទំនួលខុសត្រូវនិងការខិតខំប្រឹងប្រែងដោយខ្លួនឯងផង និងពីខាង PPWSA ផង យើងខ្ញុំបានបំពេញកិច្ចខិតខំប្រឹងប្រែងជាមួយអ្នកជំនាញការជប៉ុននៃក្រុង Kitakyushu ជាមួយនឹងស្មារតីប្រយោជន៍អ្នកដទៃ។ នោះជាមូលហេតុចម្បងមួយ ដែលជាភស្តុតាងរស់នៃប្រវត្តិសាស្ត្រ ដែលខិតខំធ្វើការរួមគ្នាទាំងយប់ទាំងថ្ងៃជាក់ស្តែង ដូច្នេះក្នុងនាមរូបខ្ញុំដែលបានរួមសុខរួមទុក្ខជាមួយគ្នាមកនេះ ខ្ញុំសុំធ្វើការវាយតម្លៃខ្ពស់នូវស្នាដៃនេះ។ នៅលើលោកនេះគ្មានអ្វីទៀតទាត់រហូតនោះឡើយ។ ក៏ប៉ុន្តែចំពោះមិត្តភាពរវាងរូបខ្ញុំនិងអ្នកជំនាញនៃក្រុង Kitakyushu ពុំប្រែប្រួលឡើយ យើងនឹងកាន់តែមានចំណងមិត្តភាពស្អិតរមួតថែមទៀត។



នៅមូលដ្ឋានត្រួតពិនិត្យការលេចធ្លាយទឹកពេលយប់ក្នុងខេត្តស្វាយរៀង (រូបកណ្តាល)។ លោក HIROWATARI Hiroshi មកពីក្រុង Kitakyushu (រូបទី ២ ពីឆ្វេង) ជាមួយបុគ្គលិករដ្ឋាករទឹកស្អាតកម្ពុជា

## ដំណើររយៈពេល២០ឆ្នាំ ១៩៩៩ - ២០១៩

**១៩៩៩ - ២០០២** ● ការបញ្ជូនអ្នកជំនាញឯកទេសជាបុគ្គល

**២០០១** ● ការងារដៃគូអភិវឌ្ឍខ្នាតតូច JICA (ការងារសហប្រតិបត្តិការបច្ចេកទេសនៃគម្រោង Grass Roots របស់អង្គការ JICA បច្ចុប្បន្ន)
បង្កើតប្រព័ន្ធត្រួតពិនិត្យការចែកចាយទឹកតាមរយៈការផ្តល់នាឡិកាស្ទង់ (Telemeter) ចំនួន ៣១ គ្រឿងរបស់ក្រុង Kitakyushu

**២០០៣ - ២០០៦** ● គម្រោងបណ្តុះបណ្តាលធនធានមនុស្សការងារទឹកស្អាត JICA (ជំហានទី ១)
ការថយចុះខ្លាំងនៃកម្រិតចំណុះទឹកបាត់បង់ឆ្នាំ២០០៥
ធ្វើការប្រកាសទឹកស្អាតអាចផឹកបាន

**២០០៧ - ២០១២** ● គម្រោងបណ្តុះបណ្តាលធនធានមនុស្សការងារទឹកស្អាត JICA (ជំហានទី ២)
មានសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតបានទៀតទាត់ និងសុវត្ថិភាពនៅតាមក្រុងគោលដៅទាំង ៨





ឆ្វេង៖ លោក TAKEDA Daigo ធ្វើការដឹកនាំអំពីការគ្រប់គ្រងប្រព័ន្ធបង្ហូរទឹក (ឆ្នាំ២០០៩)
ស្តាំ៖ លោក MATSUMOTO Hideharu ធ្វើការណែនាំការវិភាគគុណភាពទឹក (ឆ្នាំ២០១០)

◆ **២០១១** អភិបាលក្រុង Kitakyushu បានទទួលនូវ “គ្រឿងឥស្សរិយយស” បុគ្គលិករដ្ឋាករទឹកស្អាតចំនួន ៩នាក់ បានទទួល “មេដៃមិត្តភាព”
អភិបាលក្រុង Kitakyushu និងបុគ្គលិករដ្ឋាករទឹកស្អាតក្រុងដែលបំរើការក្នុងកិច្ចសហប្រតិបត្តិការបច្ចេកទេស ៩នាក់ បានទទួលមេដៃពីរដ្ឋាភិបាលកម្ពុជា

**២០១៣ - ២០១៨** ● គម្រោងបណ្តុះបណ្តាលធនធានមនុស្សការងារទឹកស្អាត JICA (ជំហានទី ៣)
មានការខាតបង់នៃការគ្រប់គ្រងក្នុងក្រុងចំនួន៧ ក្នុងចំណោមក្រុងទាំង៨ កំឡុងពេលចាប់ដំណើរការដំបូង ក៏ប៉ុន្តែនៅឆ្នាំ២០១៥ ការទូទាត់ថវិការបស់ក្រុងទាំង៨ មានការចំណេញប្រចាំឆ្នាំវិញ។ មានជំនួយតាក់តែងសេចក្តីព្រាង់ច្បាប់ស្តីពីទឹកស្អាតជាដើម។





ឆ្វេង៖ លោក KANEKO Naoya ធ្វើការណែនាំពីការប្រមូលប្រាក់ (ឆ្នាំ២០១៣)
ស្តាំ៖ លោក FUKAGAWA Takuya ធ្វើការណែនាំពីផែនការថ្មីនៃអាគារ (ឆ្នាំ២០១៥)

◆ **២០១៤** បុគ្គលិក ២ រូបនៃរដ្ឋាករទឹកស្អាតទទួល “គ្រឿងឥស្សរិយយស”
លោក ISHII Hideo (ឆ្វេង) និងលោក KIYAMA Satoshi (ស្តាំ) ទទួលបានមេដៃចំពោះកិច្ចសហប្រតិបត្តិការនៅខេត្តបាត់ដំបង



**២០១៨ ～** ● គម្រោងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពគ្រប់គ្រងរដ្ឋបាលទឹកស្អាតអង្គការ JICA (ដល់ខែកក្កដា ឆ្នាំ២០២២)
ការពង្រឹងរដ្ឋបាលនៃអគ្គនាយកដ្ឋានទឹកស្អាតក្រសួងឧស្សាហកម្មនិងសិប្បកម្ម

### ការពង្រីកសាជីវកម្មទឹក

**២០១០** • បង្កើតសមាគមភាពជាដៃគូសាធារណៈនិងឯកជន “សមាគមជម្រុញសាជីវកម្មទឹកក្រៅប្រទេសនៃក្រុង Kitakyushu (KOWBA) ”

**២០១១** • ទទួលការងារបន្ថែមគួប្លង់គ្រឹះសាងសង់រោងចក្រទឹកស្អាតក្រុងសៀមរាប
• បង្កើតអនុស្សរណៈទាក់ទងនឹងការកំណត់ផែនការមូលដ្ឋានរៀបចំទឹកស្អាតនៃក្រុងទាំង ៩ សំខាន់ៗ (ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ក្រុង Kitakyushu)

**២០១២** • ទទួលការងាររៀបចំទឹកស្អាតនៃ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី
• ទទួលការអង្កេតការមូលដ្ឋាន PPP (ភាពជាដៃគូសាធារណៈនិងឯកជន) នៃក្រុងកែប ខេត្តកំពត
• ទទួលការអង្កេតការត្រៀមផែនការរៀបចំពង្រីកទឹកស្អាតខេត្តបាត់ដំបង និងកំពង់ចាម ជំនួយឥតសំណងអង្គការ JICA

**២០១៣** • ទទួលការងារជំនួយបង្កើតសេចក្តីព្រាង (របបឥណទានទ្វេភាគី) JCM ចំពោះក្រុងភ្នំពេញ
• ទទួលផែនការពង្រីកទឹកស្អាតខេត្តបាត់ដំបង និងកំពង់ចាម ជំនួយឥតសំណងអង្គការ JICA ២០១៤

**២០១៤** • ទទួលការអង្កេតការត្រៀមផែនការរៀបចំពង្រីកទឹកស្អាតនៅតំបន់ក្រុងព្រះសីហនុនិងកំពត ជំនួយឥតសំណងអង្គការ JICA

**២០១៥** • ទទួលផែនការពង្រីកទឹកស្អាតកំពត ជំនួយឥតសំណងអង្គការ JICA
• ទទួលការងារផែនការលំអិតនិងការងារពង្រីកទឹកស្អាតក្រុងសៀមរាប កម្ចីឥណទានរបស់អង្គការ JICA

**២០១៦** • បង្កើតអនុស្សរណៈនៃការផ្សព្វផ្សាយនិងអភិវឌ្ឍនៃការងារទឹកស្អាតកម្ពុជា (ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រុង Kitakyushu (KOWBA)

**២០១៧** • ទទួលការអង្កេតត្រៀមផែនការរៀបចំពង្រីកទឹកស្អាតនៃខេត្តពោធិ៍សាត់ និងស្វាយរៀង ជំនួយឥតសំណងអង្គការ JICA

# ទៅកាន់អនាគត

## ការសាកល្បងថ្មីរបស់ក្រុង Kitakyushu

ការងារទឹកស្អាតពុំចប់នោះទេ។ ផ្ទុយទៅវិញ ដោយសារយើងត្រូវតែពង្រីករូបភាពផ្សេងៗតាមតម្រូវការនៃជំនាន់។ មិនត្រឹមតែប្រទេសកម្ពុជាទេ ប្រទេសជប៉ុនក៏មានការប្រែប្រួលនូវវិស័យទឹកស្អាតផងដែរ។ នៅក្នុងការប្រែប្រួលនៃជំនាន់បែបនោះ តើក្រុង Kitakyushu នឹងធ្វើការពង្រីកទៅដោយរបៀបណា?

ចាប់ពីខែកក្កដា ឆ្នាំ២០១៨ មក រដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu បានចាប់ផ្ដើម “គម្រោងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពគ្រប់គ្រងរដ្ឋបាលទឹកស្អាត” ថ្មី ដោយកិច្ចសហប្រតិបត្តិការបច្ចេកវិទ្យានៃអង្គការ JICA។ គម្រោងនេះមានគោលបំណងធ្វើការពង្រឹងសមត្ថភាពដែលអាចគ្រប់គ្រងនិងត្រួតពិនិត្យចំពោះអជីវករទឹកស្អាតឯកជននិងរដ្ឋាករទឹកស្អាតសាធារណៈចំនួន១៣ ការពង្រឹងសមត្ថភាពរបស់មន្ត្រីថ្មី ការងារគ្រប់គ្រង ការងារចេញអជ្ញាប័ណ្ណការកំហិតនិងតាមដានជាដើមចំពោះ “អគ្គនាយកដ្ឋានទឹកស្អាត” ដែលបានតម្លើងពី “នាយកដ្ឋានឧស្សាហកម្មនិងទឹកស្អាត” ស្របតាមការធ្វើកំណែទម្រង់រចនាសម្ព័ន្ធក្រសួងឧស្សាហកម្មនិងសិប្បកម្មដែលបានប្រារព្ធនាខែវិច្ឆិកា ឆ្នាំ២០១៦។ ជាពិសេស ទោះជាអជីវករទឹកស្អាតឯកជននៅកម្ពុជាមានរហូតដល់ជាង ៤០០ ក៏ដោយ ក៏ប៉ុន្តែអ្នកដែលមានអាជ្ញាបណ្ណមានត្រឹមតែ ២២៦ ក្រុមហ៊ុនប៉ុណ្ណោះ។ ចំពោះប្រទេសកម្ពុជាដែលមានថវិកាសាធារណៈមានកម្រិតនេះ ការចូលរួមពីសហគ្រាសឯកជនមានភាពចាំបាច់។ យ៉ាងណាមិញ ចំពោះការងារទឹកស្អាតដែលនៅផ្ទាល់ជាមួយការរស់នៅនិងអនាម័យរបស់ប្រជាជន ចាំបាច់ឱ្យមានប្រព័ន្ធគ្រប់គ្រងនិងស្តង់ដាគុណភាពទឹកច្បាស់លាស់។

នៅក្នុងគម្រោងនេះ មានការបញ្ជូនប្រធានក្រុមពីក្រសួងសុខាភិបាលការងារនិងសុខមាលភាពជប៉ុន រួមនឹងអ្នកជំនាញមកពីរដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu ។ មានការរំពឹងលើការពង្រីកគម្រោងនាពេលអនាគត ដែលរដ្ឋបាលមូលដ្ឋាននិងរដ្ឋាភិបាលជប៉ុនរួមសហការគ្នា។

យ៉ាងណាមិញ នៅឆ្នាំ២០១៥ ក្រុង Kitakyushu បានសម្រេចជោគជ័យជាលើកដំបូងក្នុងនាមជាអាជ្ញាធរមូលដ្ឋានជប៉ុនដែលទទួលបានការងារបង្កើតប្លង់ប្រព័ន្ធទឹកស្អាតដែលត្រូវបានសាងសង់





ឆ្វេង: លោកYAYAMA Masashi ត្រួតពិនិត្យអាគារទឹកស្អាតក្រុមហ៊ុនឯកជនក្នុងតំបន់ ( ស្តាំ ឆ្នាំ២០១៩ )
ស្តាំ: លោក AZUMA Kouki កំពុងត្រួតពិនិត្យអាគារផ្គត់ផ្គង់ទឹកស្អាតនៃក្រុមហ៊ុនទឹកស្អាតឯកជនក្នុងតំបន់ (រូបកណ្តាល) និងអ្នកជំនាញពីក្រុង Kitakyushu (ឆ្នាំ២០១៩)







ឆ្វេង៖ ការចុះអនុស្សារណៈដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រុង Kitakyushu និង KOWBA (ឆ្នាំ២០១៦)
ស្តាំ៖ ការតាំងពិព័រណ៍នៃសហព័ន្ធសាជីវករទឹកស្អាតកម្ពុជា (ឆ្នាំ២០១៩)




ផែនទីផែនការនៃការងារពង្រីកទឹកស្អាតខេត្តសៀមរាប

ដោយប្រាក់កម្ចីរបស់ជប៉ុននៅក្រុងសៀមរាប។ ព័ត៌មាននេះបានផ្ដល់ផលវិជ្ជមានចំពោះប្រវត្តិនៃវិស័យទឹកស្អាត។ គម្រោងនេះជាគម្រោងដ៏ធំមួយដែលសាងសង់នូវបណ្ដាញទឹកស្អាត (អាងស្តុបទឹក បណ្ដាញចែកចាយទឹក រោងចក្រទឹកស្អាត បណ្ដាញផ្គត់ផ្គង់ទឹក) ដែលអាចផ្គត់ផ្គង់ទឹក ៦ម៉ឺនតោន ក្នុងមួយថ្ងៃដោយប្ដូរប្រភពទឹកមកពីបឹងទន្លេសាបដែលមានប្រភពទឹកហូរហៀក្នុងខេត្តសៀមរាប ដែលធ្លាប់យកប្រភពទឹកក្រោមដីប្រើប្រាស់ពីមុន។ តាមរយៈគម្រោងនេះ បានធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពផ្គត់ផ្គង់ទឹក ហើយមិនត្រឹមតែធ្វើឱ្យបរិដ្ឋានរស់នៅនិងអនាម័យរបស់ប្រជាពលរដ្ឋប្រសើរឡើងប៉ុណ្ណោះទេ វាអាចអភិរក្សនូវក្រុមប្រាសាទអង្គរពីការបាក់ស្រុតគ្រឹះដី ដោយការបូមយកទឹកក្រោមដីនិងផ្ដល់វិភាគទានដល់ឧស្សាហកម្មទេសចរនិងសេដ្ឋកិច្ចផងដែរ។

ចំពោះការដេញថ្លៃគម្រោងលក្ខណៈអន្តរជាតិនេះ រដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu បានបង្កើត “សមាគមជម្រុញសាជីវកម្មទឹកក្រៅប្រទេសនៃក្រុង Kitakyushu (KOWBA)” ជាក្រុមដៃគូសាធារណៈនិងឯកជននៅក្នុងឆ្នាំ២០១០ ។ ក្រៅពីនោះផងដែររដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu បានទទួលការងារប្រឹក្សានៃការងារទាក់ទងនឹងទឹកស្អាតពីរដ្ឋាភិបាលកម្ពុជានិងអង្គការ JICA ក្រោយឆ្នាំ២០១១ ហើយបានធ្វើការងារទាក់ទងនឹងការរៀបចំទឹកស្អាតនៃក្រុងសែនមនោរម្យខេត្តមណ្ឌលគិរី និងក្រុងទាំង ៨ ដែលបានជួយរហូតមកនេះ។ ផ្ដើមចេញពីការងារសហប្រតិបត្តិការនៅក្រៅប្រទេសអាជ្ញាធរសាធារណៈនេះ បានបង្កើនបន្តបន្ទាប់នូវប្រព័ន្ធអាជីវកម្មសម្រាប់សហគ្រាសពាក់ព័ន្ធដទៀតផងដែរ។ សព្វថ្ងៃចំនួនសហគ្រាសជាសមាជិកនៃ KOWBA មានចំនួនលើស ១៥០ ក្រុមហ៊ុន ហើយបានធ្វើការបើកសិក្ខាសាលា និងការចូលរួមតាំងពិព័រណ៍នៅបណ្ដាប្រទេសអាស៊ីអាគ្នេយ៍មានដូចជា កម្ពុជានិងវៀតណាមជាដើមយ៉ាងសកម្ម និងកំពុងបង្កើនសមិទ្ធផលទទួលគម្រោងការងារពិតប្រាកដផងដែរ។ ម្យ៉ាងវិញទៀត នៅខែមករា ឆ្នាំ២០១៦ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រុង Kitakyushu KOWBA បានចុះអនុស្សារណៈចំពោះការផ្សព្វផ្សាយនិងអភិវឌ្ឍនៃការងារទឹកស្អាតនៅកម្ពុជា ហើយបានបន្ថែមនូវការសហប្រតិបត្តិការថែមទៀត។

# "ការចាប់ផ្តើម" នៃក្រុង Kitakyushu ដែលពុំស្គាល់ការនៅស្ងៀម

"ក្រុមហ៊ុនសេវាកម្មទឹក Kitakyushu (KWS)" ត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ២០១៥។ នេះជាចលករថ្មីមួយនៃក្រុង Kitakyushu ដែលអាចពង្រីកល្បឿនយ៉ាងលឿនដោយទន់ភ្លន់និងយ៉ាងសកម្មពីអាជីវកម្មតំបន់និងការងារក្រៅប្រទេស ដែលបញ្ចូលការងារទឹកស្អាតក្នុងក្រុងរបស់ "អង្គភាពរួមឯកជននិងសាធារណៈ" ដែលមានទុនរួមគ្នានៃរដ្ឋាករទឹកស្អាតនិងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu និងសហគ្រាសឯកជន។ យើងបានសាកសួរលោក ARITA Hitoshi ជាប្រធានក្រុមហ៊ុនអំពីការងារទឹកស្អាតនៅក្នុងសម័យថ្មីនិងក្រុមហ៊ុនរបស់លោកក្នុងនោះផងដែរ។

## ផ្តល់វិភាគទានដល់សាជីវកម្មទឹកស្អាតដោយប្រើប្រាស់នូវចំណេះដឹងដែលបុព្វបុរសបានបង្កើតតគ្នាមក

ទឹកស្អាតនៅប្រទេសជប៉ុននាពេលបច្ចុប្បន្ន កំពុងឈានដល់របត់ថ្មីមួយ។ ទោះជាចំណូលថវិកាថយចុះជាមួយនឹងការថយចុះនៃចំនួនប្រជាជនក៏ពិតមែន តែមានចំណាយលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីចំពោះភាពចាស់រេចរិលកើនឡើង ហើយការរក្សាបុគ្គលិកដែលចាំបាច់ក៏មានភាពលំបាក ដែលទាំងនេះជាបញ្ហាប្រឈមប្រទេសជប៉ុនកំពុងជួបប្រទះ។

ដូចគ្នានេះដែរ ខ្ញុំគិតថា ទីក្រុងភ្នំពេញនៃប្រទេសកម្ពុជាក៏កំពុងឈានមកដល់របត់ថ្មីមួយដែលស្រដៀងគ្នាក្នុងន័យមួយផ្សេងផងដែរ។

ជាមួយនឹងការកើនឡើងនៃតម្រូវការទឹកស្អាតដោយកំណើននៃចំនួនប្រជាជនយ៉ាងលឿន និងការរីកចំរើនសេដ្ឋកិច្ចដ៏ឆាប់រហ័សនេះ ខ្ញុំបានឮថាមានបញ្ហាផ្សេងៗកំពុងកើតឡើង។ ឆ្លងកាត់តាមបទពិសោធន៍ជាច្រើនឆ្នាំដែលមាន ក្រុមហ៊ុនសេវាកម្មទឹក Kitakyushu (KWS) មានបំណងចង់ចូលរួមដោះស្រាយបញ្ហាទីក្រុងភ្នំពេញកំពុងជួបប្រទះនោះ។




■ ក្របខណ្ឌការងារសេវាកម្មទឹក Kitakyushu



រូបជាមួយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួង-ឧស្សាហកម្មនិងសិប្បកម្មនៅក្នុងវេទិកាទឹកស្អាតជប៉ុន កម្ពុជា ដែលបានប្រារព្ធឡើងនៅក្រុង Kitakyushu នាថ្ងៃទី២៨ ខែវិច្ឆិកា (រូបឆ្វេង)

KWS Kitakyushu Water Service 株式会社 北九州ウォーターサービス

### ក្រុមហ៊ុនសេវាកម្មទឹក Kitakyushu ប្រធានក្រុមហ៊ុនលោក ARITA Hitoshi

ម្យ៉ាងទៀត ខ្ញុំយល់ឃើញថាល្បឿនគឺជារឿងសំខាន់ចំពោះការធ្វើសាជីវកម្មទឹកនៅក្រៅប្រទេស។ ការសម្រេចចិត្តភ្លាមៗជាចំនុចមិនពូកែរបស់ជនជាតិជប៉ុន ក៏ប៉ុន្តែ KWS ដោយយកព័ត៌មាននិងតម្រូវការដែលទទួលបានដោយកិច្ចសហប្រតិបត្តិការដែលធ្លាប់ធ្វើកន្លងមក និងយកប្រព័ន្ធធនធានមនុស្សនិងទំនាក់ទំនងនៃទំនុកចិត្តជាមួយនឹងប្រទេសជាដៃគូធ្វើជាគោល ដូច្នេះខ្ញុំគិតថាក្រុមហ៊ុនយើងខ្ញុំអាចដោះស្រាយនូវបញ្ហានេះបានទាន់ពេល។

ក្រុមហ៊ុន KWS ដោយយកតម្រូវការនៃរដ្ឋាភិបាលកម្ពុជាជាគោល យើងបានផ្តល់នូវប្រឹក្សានៃសំណើសហប្រតិបត្តិការជំនួយឥតសំណងចំពោះការរៀបចំហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតចំនួន ៣ ករណី។ នាថ្ងៃមុខ យើងនឹងខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការធ្វើឱ្យប្រសើឡើងនូវបរិស្ថានទឹកនៅកម្ពុជាក្នុងគោលបំណងរួមចំណែកដល់ការសម្រេចបាននូវគោលដៅថ្នាក់ជាតិនៃរដ្ឋាភិបាលកម្ពុជា CSDGs (ពង្រីកអត្រាផ្គត់ផ្គង់ទឹកនៅទីប្រជុំជនឱ្យបាន ១00% នៅត្រឹមឆ្នាំ២០២៥) និងគោលដៅ SDGs ។

មានមនុស្សជាច្រើននៃក្រុង Kitakyushu ខិតខំប្រឹងប្រែងដោះស្រាយបញ្ហា "ទឹកស្អាត" ដោយរូបភាពផ្សេងៗ។ កិច្ចខិតខំទាំងអស់ជា "រូបរាង" ដែលកើតឡើងពីការគិតមួយដែលពោលថា៖ "ចង់ផ្តល់ទឹកស្អាតដល់មនុស្សគ្រប់គ្នា"។ នៅរយៈពេល ២០ឆ្នាំ ឬ៥០ឆ្នាំទៅមុខទៀត គេនឹងខិតខំធ្វើការផ្សេងៗ ដោយយកមិត្តភាពដែលបានចិញ្ចឹមបីបាច់រហូតមកនេះជាមូលដ្ឋានគ្រឹះ ដើម្បីដើរទៅមុខជាមួយនឹងប្រទេសកម្ពុជាជាក់ជាមិនខាន។ នៅពេលខាងមុខនោះប្រហែលជានឹងមាន "អច្ឆរិយនៃកម្ពុជា" កើតឡើង។

# សារទាំងឡាយពីមិត្តភក្តិនៃក្រុមការងារទឹកស្អាត

បុគ្គលិកទឹកស្អាតកម្ពុជានិងក្រុង Kitakyushu បានសហការជាមួយគ្នារយៈពេល ២០ ឆ្នាំមកហើយ។ មានសារពី "យុវជនទឹកស្អាត" ដែលពេលខ្លះធ្លាប់មានការឈ្លោះប្រកែកគ្នា ពេលខ្លះពុំអាចយល់គ្នា ពេលខ្លះទឹកភ្នែកជាមួយគ្នា ហើយពេលខ្លះលើកទឹកចិត្តគ្នាទៅវិញទៅមក បានមកដល់!

## ▼ ពីមិត្តភក្តិនៃក្រុង Kitakyushu

ខ្ញុំជាបុគ្គលទី ២ ដែលត្រូវបានបញ្ជូនមកកម្ពុជាពីក្រុង Kitakyushu ចាប់ពីខែឧសភា ឆ្នាំ២០០០ ដល់ខែកុម្ភៈ ឆ្នាំ២០០១ មានរយៈពេល ៩ ខែ។ កាលនោះ ខ្ញុំគិតថានៅមានចំនួនជនជាតិជប៉ុនតិចតួចនៅឡើយ ហើយចាំបានទៀតថា ពិតជាមានការលំបាកក្នុងការស្វែងរកហាងលក់ម្ហូបជប៉ុននៅកម្ពុជា។ តាមខ្ញុំចាំពេលនោះ ទស្សនាវដ្តីញញឹមក៏មិនទាន់បានចេញផ្សាយផងដែរ។ នៅឆ្នាំ២០១៣ វាមានរយៈពេល ១៣ ឆ្នាំដែលខ្ញុំត្រូវបានបញ្ជូនមកកម្ពុជាសារជាថ្មី ឃើញថាមានហាងម្ហូបជប៉ុនក៏ច្រើន ហើយសុវត្ថិភាពក៏ល្អប្រសើរច្រើន។ ម្យ៉ាងទៀតពេលនោះ ខ្ញុំនៅចាំបានថា ខ្ញុំមានអារម្មណ៍ត្រេកអរជាខ្លាំងដែលបានជួបនឹងបុគ្គលិករបស់ PPWSA សារជាថ្មី ដែលបានបែកគ្នាប្រហែល ១៣ ឆ្នាំមុន ដោយគាត់នៅចាំខ្ញុំច្បាស់។ កាលខ្ញុំមករស់នៅប្រទេសកម្ពុជារយៈពេល ៩ ខែដំបូង ខ្ញុំទទួលបានការជួយជ្រោមជ្រែងពីសំណាក់បុគ្គលិកនៃ PPWSA ផងដែរ ដែលនាំឱ្យខ្ញុំអាចខិតខំប្រឹងប្រែងបំពេញការងារបាននាពេលនោះ។ សូមឱ្យទំនាក់ទំនងមិត្តភាពរវាងកម្ពុជានិងក្រុង Kitakyushu បន្តល្អទៅមុខទៀត។ (លោក UEDA Tetsuya)



ខ្ញុំបានមកប្រទេសកម្ពុជាជាលើកដំបូងកាលពី ១០ឆ្នាំមុន ពោលគឺនៅឆ្នាំ២០០៩ ហើយបច្ចុប្បន្នខ្ញុំបានផ្លាស់មករស់នៅកម្ពុជាជាមួយប្រពន្ធនិងកូនរបស់ខ្ញុំក្នុងនាមជាអ្នកជំនាញឯកទេសរយៈពេលវែង។ ខ្ញុំនឹងខិតខំប្រឹងប្រែងបន្តទៀតនៅឆ្នាំ២០២០ផងដែរ។ (លោក YAYAMA Masashi)

ខ្ញុំបានមកប្រទេសកម្ពុជាក្នុងខេត្តកំពត ដែលជាការចេញទៅបំរើការនៅបរទេសជាលើកដំបូងសម្រាប់ជីវិតរបស់ខ្ញុំក្នុងនាមជាអ្នកដឹកនាំការងារគ្រប់គ្រងថែរក្សាទឹកស្អាត។ វាជាការងារលើកដំបូងរបស់ខ្ញុំ ដូច្នេះវាពិតជាបទពិសោធន៍ដ៏ល្អមួយសម្រាប់ខ្ញុំ។ (លោក MIYASHITA Yoshiyuki)

អ្វីដែលខ្ញុំយល់ឃើញនិងនិយាយដោយត្រង់ ក្នុងរយៈពេល ៣ឆ្នាំ នៅកម្ពុជាគឺប្រជាជនមានការគិតវិជ្ជមានស្មោះត្រង់ និងម៉ឺងម៉ាត់ចំពោះការងារ។ ក៏ប៉ុន្តែ ខ្ញុំមានអារម្មណ៍ថាដូចជានិយាយត្រង់ពេកហើយ....(សើច) (លោក HIRATA Kenjirou)

មានរយៈពេលត្រឹមតែកន្លះឆ្នាំក៏ពិតមែន ខ្ញុំពិតជាពេញចិត្តនឹងការរស់នៅបំរើការងារនៅកម្ពុជាទាំងការងារសាធារណៈនិងឯកជន។ ចំពោះការងារវិញ ខ្ញុំមានការលំបាកក្នុងការប្រើភាសាអង់គ្លេស តែខ្ញុំសប្បាយចិត្តបើអ្នកទាំងអស់គ្នាបានរៀនអ្វីបន្តិចបន្តួចពីខ្ញុំ។ ពេលខ្លះចង់ញុំាកាហ្វេធម្មតា ពេលញុំាការហ្វេដាក់ទឹកដោះគោផ្អែមច្រើន ដែលខ្ញុំបានញុំារាល់ព្រឹកនោះ។ (លោក SAKAE Shuichi)

The best way to find out if you can trust somebody is to trust them. (SATO Yuichirou)



ខ្ញុំបានធ្វើដំណើរទូទាំង ៨ ក្រុងក្នុងរយៈពេល ៣ខែ ខ្ញុំសុំអភ័យទោសដោយសារតែចំណេះដឹងនិងសម្ថភាពភាសា ខ្ញុំមានកម្រិតតែវាជាអនុស្សាវរីយ៍ដ៏ល្អមួយដែលបានអនុវត្តជាមួយបុគ្គលិកមូលដ្ឋាន នូវការជួសជុលឧបករណ៍វាស់ទឹកនិងធ្វើការងារត្រួតពិនិត្យការលេចធ្លាយទឹកនៅពេលយប់ជាដើម។ (លោក NISHIDA Takatomo)



របបបញ្ចូលក្លរីននិងវាស់កម្រិតជាតិអំបិលកាន់បំពង់ផ្គត់ផ្គង់ទឹករាល់ ២ ដងក្នុង ១ ខែ ដែលដឹកនាំដោយជំហានទី ២ នៃគម្រោងបណ្តុះបណ្តាលធនធានមនុស្ស តែជំហានទី ២ ចប់ក្តី គម្រោងត្រូវបានបន្តដោយបុគ្គលិកនៃរដ្ឋាករទឹកស្អាតប្រចាំមូលដ្ឋាន ហើយខ្ញុំមានអារម្មណ៍ត្រេកអរនៅពេលឃើញសកម្មភាពខិតខំផ្គតផ្គង់ទឹកស្អាតនោះ។ (លោក KAGATA Katsutoshi)

## ▼ សារពីបុគ្គលិកទឹកស្អាតកម្ពុជា!





ផ្នែកមួយនៃកម្មសិក្សានៅក្រុង Kitakyushu។ រូបភាពញុំាអាហារជុំគ្នាក្រោយកម្មសិក្សាចប់ដោយជោគជ័យ!

ខ្ញុំសូមថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការជាយូឆ្នាំ ក្នុងឱកាសខួបលើកទី ២០ ឆ្នាំនេះ។ ចំពោះរូបខ្ញុំដែលបំរើការផ្នែកទឹកស្អាតនេះ ក្រុង Kitakyushu ជា "ទឹកដីនៃក្តីសង្ឃឹម"។ សូមក្រុង Kitakyushu បន្តនៅជាស្ពានភ្ជាប់មិត្តភាពនៃប្រទេសកម្ពុជានិងជប៉ុនទៅថ្ងៃមុខទៀត។ (លោក SRENG Sokvung ប្រធានក្រុមការងារគម្រោងនិងបច្ចេកទេសនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម)



# ជាមួយអ្នកទាំងអស់គ្នាដែលប្រាស្រ័យរស់នៅជាមួយទឹក

នៅក្នុងទស្សនាវដ្ដីញញឹមខ្មែរលេខនេះ បានលើកឡើងអំពីការចុះផ្សាយពិសេសស្ដីពីការប្រារព្ធខួបអនុស្សាវរីយលើកទី ២០ នៃកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជាជាមួយរដ្ឋាករទឹកស្អាត និងប្រព័ន្ធអនាម័យនៃក្រុង Kitakyushu ។ តាមពិតទៅគម្រោងទឹកស្អាតនេះជាចំនុចចាប់ផ្ដើមនៃជីវិតការងារបកប្រែរបស់នាងខ្ញុំ។

រឿងនេះបានចាប់ផ្ដើមកាលពី ២០ ឆ្នាំមុន។ កាលនោះ នាងខ្ញុំជានិស្សិតឆ្នាំទី ៣ ផ្នែកអក្សរសាស្ត្រខ្មែរនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយថ្ងៃមួយ នាងខ្ញុំបានទទួលការ “កោះហៅ” ពីគេ។ “គេត្រូវការអ្នកបកប្រែម្នាក់ព្រោះមានសិក្ខាសាលាអំពីការងារទឹកស្អាត”។ កាលនោះ នាងខ្ញុំដែលជានិស្សិតដែលទើបបានចាប់ផ្ដើមការងារបកប្រែបន្តិចបន្តួចក៏បានជិះកង់សំដៅទៅរដ្ឋាករទឹកស្អាតក្រុងភ្នំពេញ (PPWSA) ភ្លាម ហើយបានជួបលោក KUBOTA Kazuya ដែលត្រូវបានបញ្ជូនមកពីក្រុង Kitakyushu។

បុរសម្នាក់ដែលនិយាយភាសាបែបអ្នកក្រុង Kitakyushu បានហុចនូវឯកសារដ៏ពិបាកយល់មួយមកឲ្យនាងខ្ញុំហើយបាននិយាយថា “តើនាងបកប្រែកើតទេ? លើកនេះយើងនឹងរៀបចំសិក្ខាសាលា។ សុំពឹងជួយបកប្រែឲ្យផងបានទេ?”។ វាជាសិក្ខាសាលាដែលធ្វើបទបង្ហាញស្ដីពី “ប្រព័ន្ធវាស់ស្ទង់ដោយប្រើ Telemeter”។ វាពិតជាពិបាកមែន។ តើនាងខ្ញុំត្រូវបកប្រែពាក្យដែលទាក់ទងនឹងជំនាញការងារទាំងនោះដូចជា៖ ការបញ្ជូនទិន្នន័យដោយប្រើប្រព័ន្ធខ្សែអុបទិចជាដើម ដោយរបៀបណា? នាងខ្ញុំបានធ្វើការងារបកប្រែនោះជាលើកទីមួយ សម្រាប់ជាបទពិសោធន៍នៃការរៀនសូត្រមួយរបស់នាងខ្ញុំ។

ប៉ុន្មានឆ្នាំនោះក្រោយមក មានការ “កោះហៅ” មួយទៀតបានមកដល់ពីលោក KIYAMA Satoshi ដែលជាអ្នកជំនាញរយៈពេលវែងពីអង្គការ JICA។ នៅលើដំបូលអាគារនៃរដ្ឋាករទឹក PPWSA ដែលកាលនោះនៅមានបឹងកក់នៅក្បែរនៅឡើយ ក្រុមការងារមកពីក្រុង Kitakyushu និង ឯកឧត្ដម ឯក សុនចាន់ ជាអគ្គនាយកនៃ PPWSA (កាលនោះ) បានទស្សនាថ្ងៃលិចបណ្ដើរ និយាយអំពីការងារពង្រីកទឹកស្អាតដ៏ធំមួយនៅថ្ងៃមុខក្នុងក្រុងភ្នំពេញបណ្ដើរ។ នៅពេលនោះ ស្រាប់តែលោក KIYAMA បាននិយាយលោមដល់នាងខ្ញុំថា “នាងអាចមកក្រុង Kitakyushu បានទេ?” ដោយគាត់យកដៃដាល់ជញ្ជាំងហើយសម្លឹងមើលភ្នែករបស់នាងខ្ញុំ។ ចំពោះស្ថានភាពដ៏អណ្ដែតអណ្ដូងបែបនោះ (កំឡុងពេលមានថ្ងៃលិចនៅលើបឹងកក់ ជាមួយខ្យល់បក់ល្ហើយតិចៗផង) នាងខ្ញុំក៏បានយល់ព្រមពីការស្នើសុំភ្លាមៗ។

ចាប់ពីឆ្នាំ២០០៩ មក នាងខ្ញុំក៏បានធ្វើដំណើរទៅមកក្រុង Kitakyushu ជារៀងរាល់ឆ្នាំ។ នាងខ្ញុំបានចូលរួមកម្មវិធីកម្មសិក្សាជាមួយសិក្ខាកាមជាច្រើន ដែលពេលខ្លះមានរយៈពេលវែងបំផុតរហូតដល់ ២ខែក៏មាន ដោយធ្វើការរស់នៅនិងញ៉ាំម្ហូបអាហាររួមគ្នានឹងសិក្ខាកាមកម្ពុជា។ មានការងារបកប្រែជាច្រើនទាក់ទងនឹង “ទឹកស្អាត” ដែលមានតាំងពីការងារបច្ចេកទេសដូចជា៖ ប្រភេទនៃតំណភ្ជាប់បំពង់ទឹក របៀបដាក់កម្លាំងរឹតខ្ចៅ ការងារលើកឡើងនិងទម្លាក់ចុះនៃបំពង់ទឹកដោយឡានស្ទូចការត្រួតពិនិត្យការលេចធ្លាយទឹក ការធ្វើតេស្តគុណភាពទឹក ការត្រួតពិនិត្យគុណភាពទឹកសាមញ្ញនៅចុងបណ្ដាញ ការកំណត់ប្លង់ប្រព័ន្ធបំពង់បង្ហូរទឹកជាដើម រហូតដល់ការគ្រប់គ្រងរួមនៃការងារទឹកស្អាតដែលមានដូចជា៖ ការកំណត់ផែនការគ្រប់គ្រង និងការគ្រប់គ្រងព័ត៌មានអតិថិជនជាដើមទៀតផងដែរ។ តាមរយៈការងារទាំងនេះបាននាំឲ្យនាងខ្ញុំស្រម៉ៃថា “នៅថ្ងៃអនាគត នាងខ្ញុំនឹងអាចក្លាយទៅជាប្រធានរដ្ឋាករទឹកបានជាមិនខាន” ហើយចាប់ពីឆ្នាំនោះទៅនាងខ្ញុំបានចាប់ផ្ដើមធ្វើការរៀនសូត្រថ្មី រួមជាមួយមន្ត្រីវ័យក្មេងនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដែលមានតួនាទីត្រួតពិនិត្យនិងតាមដានមើលលើការងារទឹកស្អាតនៅទូទាំងប្រទេសកម្ពុជា។

សិក្ខាកាមនៃជំនាន់នីមួយៗឧស្សាព្យាយាមជាខ្លាំង ជាពិសេសក្នុងកម្មសិក្សានៅឆ្នាំនេះ នាងខ្ញុំសង្កេតឃើញមានការ “សួរដេញដោលជាច្រើន”។ ការបកប្រែពីសំណួរមួយទៅសំណួរមួយទាំងនោះគឺពិតជាមានការលំបាក។ នៅចុងបញ្ចប់នៅពេលប្រកាសថា “ម្នាក់សួរបានតែ ២សំណួរប៉ុណ្ណោះ! តែបើនៅតែមានសំណួរច្រើនទៀតនោះ មួយសំណួរត្រូវបង់ ៥០០យ៉េន! ហើយប្រមូលប្រាក់ទាំងនោះទុកផឹកស៊ីនៅយប់នេះ!” និយាយដូចនេះហើយអ្នកទាំងអស់គ្នាក៏បានសើចឡើង។ សិក្ខាកាមទាំងអស់បានត្រឡប់មកកម្ពុជាវិញ ជាមួយនឹងការស្រូបយកនូវចំនេះដឹងជាច្រើនតាមរយៈការសួរសំណួរផ្សេងៗដែលថាមួយសំណួរ ៥០០យ៉េន (សើច)។

នាងខ្ញុំហៅអ្នកដែលនាងខ្ញុំបានជួបទាំងនោះនៅក្រុង Kitakyushu និងកម្ពុជានេះថា “ជាមិត្តរីករាយ”។ ពួកយើងពិតជារីករាយ តែចំពោះការងារទឹកស្អាតវិញពិតជាម៉ត់ចត់ ហើយយើងជាមិត្តសម្លាញ់នឹងគ្នា។ ទៅថ្ងៃមុខ យើងនឹងរួមគ្នាបង្កើត “ទឹកស្អាតសម្រាប់អ្នកទាំងអស់គ្នា” ដោយនិយាយជាមួយនឹងរឿង “ប្រាំរយៗ” នេះជាមួយគ្នា។ សារជាថ្មីម្ដងទៀត នាងខ្ញុំសូមអបអរសាទរនូវខួបអនុស្សាវរីយលើកទី ២០នេះ!









## គយគន់ទេសភាពប្រទេសជប៉ុន

# ប្រាសាទបន្ទាយទ័ពក្នុងអតីតកាល

ប្រាសាទ Kokura (Kokura-jo) ដែលបែរមុខសំដៅទៅច្រកសមុទ្រ Kanmon ស្ថិតនៅចន្លោះកោះ Honshu និងកោះ Kyushu នៃប្រទេសជប៉ុន ជាទីកន្លែងដែលប្រាសាទនិងបន្ទាយទ័ពជាដើម ត្រូវបានសាងសង់ឡើងពីបុរាណកាលមកជាចំនុចសំខាន់នៃចរាចររបស់ទ័ពជើងទឹក និងជើងគោក។ “ប្រាសាទ Kokura” ស្ថិតនៅសង្កាត់ Kokurakita នៃក្រុង Kitakyushu ជាប្រាសាទដ៏មានកេរ្តិ៍ឈ្មោះល្បីល្បាញមួយផងដែរនៅក្នុងប្រទេសជប៉ុន។

ប្រាសាទនេះត្រូវបានសាងសង់ឡើងជាលើកដំបូងកាលពីប្រមាណ ៧៥០ ឆ្នាំមុន។ បើនិយាយពីប្រទេសកម្ពុជាគឺត្រូវនឹងសម័យកាលសាងសង់ប្រាសាទអង្គរវត្ត។ ប្រមាណ ៤០០ឆ្នាំមុន តួប៉មប្រាសាទដែលមានទម្រង់ដូចបច្ចុប្បន្នត្រូវបានសាងសង់ឡើងដោយចំណាយពេលប្រមាណ ៧ឆ្នាំ ហើយគេចាត់ទុកវាជាប្រសាទដែលការពារទីក្រុង ដោយត្រូវបានសាងសង់បែរត្រង់ទៅសមុទ្រ។ ក៏ប៉ុន្តែ កាលពីប្រមាណ ១៨០ ឆ្នាំមុន ប្រាសាទនេះត្រូវបានឆេះដោយសារគ្រោះធម្មជាតិ ហើយក្រោយមកទៀត ត្រូវបានបំផ្លាញដោយសារឥទ្ធិពលនៃសង្គ្រាម ដែលនាំឲ្យទម្រង់ប្រាសាទខូចខាតទាំងស្រុង ក៏ប៉ុន្តែនៅឆ្នាំ១៩៥៩ ប្រសាទនេះត្រូវបានសាងសង់ឡើងសារជាថ្មី ដោយយោងតាមកំណត់ត្រាគំរូពីអតីតកាល។

បច្ចុប្បន្ន វាបានក្លាយជាតំបន់ទេសចរមួយដ៏ល្បីល្បាញនៅក្នុងទីក្រុង Kitakyushu ដែលមានភ្ញៀវទេសចរជាតិនិងអន្តរជាតិជាច្រើនមកទស្សនាដោយថ្មើរជើងពីស្ថានីយរថភ្លើងលឿន Shinkansen និង រថភ្លើងធម្មតា។ ជាពិសេសនៅខែមិនា និងខែមេសា មានផ្កាសាគូរ៉ារីកស្គុះស្គាយនៅក្នុងទីធ្លានៃតួប៉មកណ្តាលនៃប្រាសាទ ហើយវាក៏ជាទីកន្លែងដ៏មានប្រជាប្រិយមួយផងដែរសំរាប់ការមើលផ្ការីក ដែលមានមនុស្សជាច្រើនមកទស្សនាជារៀងរាល់ឆ្នាំ។




Kokura Castle (Kokura-jo),
Kitakyushu City,
Fukuoka Prefecture

នាខែមិនា ឆ្នាំ២០១៩ គេបានសាងសង់សារជាថ្មីនូវផ្នែកកណ្តាលនៃតួប៉មប្រាសាទ។ ម្យ៉ាងទៀត នៅក្នុងបរិវេណសួនឧទ្យានក្បែរប្រាសាទ Kokura ក៏មានប្រារព្ធពិធីនានាដូចជា៖ ពិធីធ្វើនំគោមនិងការផុងតែបែបប្រពៃណីជប៉ុន ការតាំងពិពណ៌រូបភាព ការផ្សាយផ្ទាល់នៃការប្រគំតន្ត្រី និងពិធីរត់កីឡាម៉ារ៉ាតុងជាដើម ដែលភ្ញៀវទេសចរអាចកម្សាន្តបានគ្រប់រដូវកាល។ សូមលោកអ្នកអញ្ជើញទៅទស្សនាទីក្រុង Kitakyushu នៅក្នុងដំណើរកម្សាន្តទៅកោះ Kyushu នៃប្រទេសជប៉ុនទាំងអស់គ្នា!